**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

**គម្រោងអភិបាលកិច្ចល្អមូលដ្ឋាន**

**ការិយាល័យសម្របសម្រួលគម្រោង**

# សេចក្តីប្រកាសជ្រើសរើសអ្នកហាត់ការ

គម្រោងអភិបាលកិច្ចល្អមូលដ្ឋានបានទទួលជំនួយឥតសំណង ពីសមាគមន៍អភិវឌ្ឍន៍អន្តរជាតិ (IDA) នៃធនាគារពិភពលោក ចំនួន **២០** លានដុល្លារសហរដ្ឋអាមេរិក តាមរយៈរាជរដ្ឋាភិបាលកម្ពុជាក្នុងរយៈពេល ០៤ ឆ្នាំ (២០០៩-២០១៣) ដើម្បីអនុវត្ត និងជំរុញអោយមានអភិបាលកិច្ចល្អមូលដ្ឋានតាមរយៈការពង្រឹងសមត្ថភាពស្ថាប័ន គាំទ្រភាពជាដៃគូរ និងផ្លាស់ប្តូរបទពិសោធន៍ ក្រោមការសម្របសម្រួលដោយក្រសួងមហាផ្ទៃ ដែលជាភ្នាក់ងារដឹកនាំប្រតិបត្តិ។

គម្រោងអភិបាលកិច្ចល្អមូលដ្ឋាន នៃក្រសួងមហាផ្ទៃ សូមជូនដំណឹងដល់និស្សិតទាំងពីរភេទ ដែលបានបញ្ចប់ការសិក្សា និងកំពុងសិក្សាឆ្នាំទី៤ អោយបានជ្រាបថា គម្រោងអភិបាលកិច្ចល្អមូលដ្ឋាននឹងធ្វើការជ្រើសរើសអ្នកហាត់ការ អោយបំពេញការងារនៅក្នុងការិយាល័យសម្របសម្រួលគម្រោង ចំនួន ៥រូប សំរាប់រយៈពេល ០៦ខែ។

## ១. មុខតំណែងត្រូវជ្រើសរើស

| | |
|---|---|
| ១- អ្នកហាត់ការផ្នែកគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស | ចំនួន ១ រូប |
| ២- អ្នកហាត់ការផ្នែកព័ត៌មានវិទ្យា និងទំនាក់ទំនង | ចំនួន ១ រូប |
| ៣- អ្នកហាត់ការផ្នែកភាពជាដៃគូ និងការចូលរួម | ចំនួន ២ រូប |
| ៤- អ្នកហាត់ការផ្នែកលទ្ធកម្ម | ចំនួន ១ រូប |

## ២. លក្ខណៈសម្បត្តិនៃការជ្រើសរើស

បេក្ខជន-បេក្ខនារីត្រូវមានសមត្ថភាពគ្រប់គ្រាន់អាចអនុវត្តមុខតំណែងនោះបាន ហើយត្រូវមាន :

- បរិញ្ញាប័ត្រ រឺកំពុងសិក្សាឆ្នាំទី ៤
- ត្រូវមានជំនាញ ទាក់ទងទៅនឹងមុខតំណែង
- សមត្ថភាពភាសាអង់គ្លេសអាចប្រើប្រាស់បាន
- ជំនាញប្រើប្រាស់កម្មវិធីកុំព្យូទ័រ

តួនាទី និងភារកិច្ច និងលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសលំអិតមានភ្ជាប់នៅក្នុងទម្រង់ការពិពណ៌នាមុខតំណែង នៃតំណែងនីមួយៗ។

**៣. សំណុំលិខិត និងការដាក់ពាក្យ**

ជីវប្រវត្តិសង្ខេប ចំនួន ០១ ច្បាប់

**៤. កាលបរិច្ឆេទ និង ទីកន្លែងទទួលពាក្យ**

កាលបរិច្ឆេទទទួលពាក្យ : ចាប់ពីថ្ងៃទី២៥ ខែមេសា ដល់ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១១ វេលាម៉ោង ០៥:៣០ ល្ងាច

កន្លែងទទួលពាក្យ : ការិយាល័យសម្របសម្រួលគម្រោង ក្រសួងមហាផ្ទៃ បន្ទប់ ២១៤ អាគារទីស្តីការក្រសួងមហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

ទំនាក់ទំនង លោក **សំ ធារ៉ា** ប្រធានផ្នែកគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស

ទូរស័ព្ទ ០២៣ ៧២៦ ៩៥៦/០១២ ៩២២ ២៣៣

រឺផ្ញើមកកាន់ E-mail: dfgg.recruitment@gmail.com

អាស្រ័យហេតុនេះ និស្សិតទាំងពីរភេទ ដែលមានលក្ខណៈសម្បត្តិដូចបានកំណត់ក្នុងឧបសម្ព័ន្ធនៃសេចក្តីជូនដំណឹងនេះ មានបំណងហាត់ការងារនៅក្នុងគម្រោង សូមផ្ញើជីវប្រវត្តិសង្ខេប ដោយបញ្ជាក់អោយបានច្បាស់អំពីតំណែងដែលស្នើសុំ មកកន្លែងទទួលពាក្យស្នើសុំ ដែលមានអាស័យដ្ឋានដូចមានកំណត់ខាងលើ ។ ស្ត្រីត្រូវបានលើកទឹកចិត្តក្នុងការស្នើសុំ ។